# យើងខ្ញុំនឹងរក្សាព័ត៌មានរបស់លោកអ្នកជាការសម្ងាត់

អ្វីដែលលោកអ្នកប្រាប់យើងខ្ញុំគឺជាការសម្ងាត់។ នេះមានន័យថា យើងខ្ញុំមិនអាចប្រាប់នរណាម្នាក់ពីអ្វីដែលលោកអ្នកនិយាយ ឬផ្តល់ឱ្យយើងខ្ញុំទេ - លើកលែងតែលោកអ្នកយល់ព្រម។

ជួនកាល Legal Aid (ជំនួយផ្លូវច្បាប់) ជួយមនុស្សច្រើនជាងម្នាក់ក្នុងករណីដូចគ្នា។ យើងខ្ញុំមានមេធាវីជាច្រើន។ ដូច្នេះ មេធាវីម្នាក់របស់យើងខ្ញុំអាចជួយលោកអ្នក ហើយមេធាវី Legal Aid ផ្សេងទៀតអាចជួយអ្នក ដែលមានជម្លោះជាមួយលោកអ្នក។

ឬមេធាវីផ្សេងទៀត ក៏ប្រហែលជាអាចជួយអ្នកដទៃទៀតផងដែរដែល ជាប់ទាក់ទិននឹងករណីរបស់លោកអ្នក។

ប្រសិនបើលោកអ្នកយល់ព្រមទទួលយកជំនួយរបស់យើងខ្ញុំ នោះលោកអ្នកយល់ស្របនឹងវិធីដែលយើងខ្ញុំចាត់ចែងព័ត៌មានសម្ងាត់របស់លោក អ្នក។

## មេធាវីរបស់លោកអ្នក នឹងមានព័ត៌មានអំពីលោកអ្នកតែប៉ុណ្ណោះ

នេះមានន័យថា មេធាវីរបស់លោកអ្នកនឹងមិន៖

- ដឹងពីអ្វីសោះឡើយអំពីបុគ្គលផ្សេងទៀត
- ទទួលបានព័ត៌មានអំពីបុគ្គលផ្សេងទៀត និង
- ចែករំលែកព័ត៌មានអំពីលោកអ្នក ជាមួយមេធាវីរបស់បុគ្គលផ្សេងទៀត។

ហើយមេធាវីរបស់បុគ្គលផ្សេងទៀត នឹងមិនដឹងពីអ្វីសោះអំពីលោកអ្នក ឬករណីរបស់លោកអ្នក។

## តើលោកអ្នកមានសំណួរណាមួយឬទេ?

ប្រសិនបើលោកអ្នកមានសំណួរណាមួយ អំពីរបៀបដែលយើងខ្ញុំចាត់ចែង ព័ត៌មានសម្ងាត់របស់លោកអ្នក សូមសួរមេធាវី មុនពេលលោកអ្នកប្រាប់ពួកគេអំពីបញ្ហាច្បាប់របស់លោកអ្នក។

Legal Aid NEW SOUTH WALES